ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៣ លេខ ០៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

Work Activities

ប្រចាំខែ កញ្ញា ឆ្នាំ ២០១០



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពី គោលការណែនាំសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនិងយន្តការត្រួតពិនិត្យ ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត នៅព្រះរាជាណាចក្រកម្ពុជា | ១-២ |
| ២- | សេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈអាជ្ញាសាលា | ៣ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលសមាសភាព គណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស | ៤-៥ |
| ៤- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតកាយរឹទ្ធិជាតិកម្ពុជា និងសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរឹទ្ធិជាតិកម្ពុជា | ៦ |
| ៥- | កិច្ចប្រជុំឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា | ៧ |
| ៦- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១០ | ៨ - ១២ |
| ៧- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ - ១៧ |

### សេចក្តីព្រាងអនុក្រឹត្យស្តីពី

# គោលការណ៍ណែនាំសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនិងយន្តការត្រួតពិនិត្យ ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅព្រះរាជាណាចក្រកម្ពុជា

កាលពីថ្ងៃទី១ ទី២ ទី១៥ និងទី២៩ ខែកញ្ញា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនិងយន្តការត្រួតពិនិត្យ ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅព្រះរាជាណាចក្រកម្ពុជា ដោយមានការអញ្ជើញចូលរួមពីតំណាងគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីដឹកនាំការពារសារណា និងនិក្ខេបបទ សមាជិក និង អគ្គលេខាធិការរងនៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



ថ្លែងក្នុងពិធីសន្និបាតជាតិអប់រំ និងពិធីចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យអន្តរជាតិ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានប្រគល់ភារកិច្ចជូនគណៈកម្មាធិការទទួលបន្ទុកគុណភាពអប់រំនៃកម្ពុជានៃទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យគ្រោងរៀបចំបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីរៀបចំគោលការណ៍ណែនាំ និងនីតិវិធីដឹកនាំការពារសារណា និងនិក្ខេបបទថ្នាក់ក្រោយឧត្តមសិក្សា ដើម្បីឱ្យការបណ្តុះបណ្តាលមានគុណភាពនិងមានការឯកភាពគ្នាក្នុងការអនុវត្តនៅទូទាំងប្រទេស ព្រមទាំងឱ្យស្របតាមបរិបទក្នុងតំបន់ និងពិភពលោក ព្រោះកន្លងមក មានបញ្ហាចោទដែលលេចឡើងក្នុងបរិបទឧត្តមសិក្សាបច្ចុប្បន្ន គឺសាស្ត្រាចារ្យមួយរូបអាចដឹកនាំនិស្សិតថ្នាក់បណ្ឌិតរហូតទៅដល់ ១០០នាក់ ដែលនាំឱ្យគុណភាពនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិតចុះខ្សោយ។ ម្យ៉ាងទៀតសម្រាប់ប្រទេសកម្ពុជាយើងបច្ចុប្បន្ន ក៏ពុំទាន់មានគោលការណ៍ច្បាស់លាស់ណាមួយ ក្នុងការណែនាំការបណ្តុះបណ្តាលកម្រិតក្រោយឧត្តមសិក្សានៅឡើយ។

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៧៩ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណា និងនិក្ខេបបទ ដែលមានសមាសភាពជាបណ្ឌិតជាច្រើនរូប ដើម្បីរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនិងយន្តការត្រួតពិនិត្យ ដើម្បីធានា

គុណភាពនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត នៅព្រះរាជាណាចក្រកម្ពុជា(១)។

អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះដោយយកចិត្តទុកដាក់ ហើយបានសម្រេចកែសម្រួលចំណងជើង ទៅជា " **អនុក្រឹត្យស្តីពី ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត** " ព្រោះកន្លងមកគោលការណ៍ណែនាំត្រូវរៀបចំឡើងដោយសារាចររបស់ក្រសួងពាក់ព័ន្ធ កែសម្រួលពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីឱ្យងាយយល់ និងមានអត្ថន័យពេលលេញ និងបង្កើត “ ប្រភេទសញ្ញាបត្របណ្ឌិត ” ដើម្បីឱ្យសេចក្តីព្រាងអនុក្រឹត្យនេះ មានលក្ខណៈគ្រប់គ្រាន់។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងយន្តការត្រួតពិនិត្យ ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅព្រះរាជាណាចក្រកម្ពុជា។

## សេចក្តីព្រាងច្បាប់ស្តីពី

# លក្ខន្តិកៈអាជ្ញាសាលា

កាលពីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡៃន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ចិន្តធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈអាជ្ញាសាលា** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងយុត្តិធម៌ សមាជិក និង អគ្គលេខាធិការរងនៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងយុត្តិធម៌ បានរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈអាជ្ញាសាលា ដោយមានគោលបំណងកំណត់អំពីឋានៈ ការចាត់តាំង ការបញ្ឈប់ ការអនុវត្តមុខងារ និងរបបកម្រៃរបស់អាជ្ញាសាលា ដូចដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

យោងតាមគន្លឹទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី អាជ្ញាសាលាមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត៖

- ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើ ទ្រព្យសម្បត្តិផ្សេងទៀត ដែលទាក់ទងនឹងចលនវត្ថុ



-ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

-ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ

- ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ

-ការប្រតិបត្តិការបញ្ជូន

-ការបំពេញតួនាទីជាអ្នកជំនួយនៅពេលដែលមានការស្នើសុំដោយអ្នកបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ

-ការប្រគល់ឯកសារបម្លងយថាភូតនៃសំណុំរឿងពាក់ព័ន្ធនឹងរឿងក្តី

-ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

-ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ -ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ -ការប្រតិបត្តិការបញ្ជូន

-ការបំពេញតួនាទីជាអ្នកជំនួយ នៅពេលដែលមានការស្នើសុំដោយអ្នកបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ

-ការប្រគល់ឯកសារបម្លងយថាភូតនៃសំណុំរឿងពាក់ព័ន្ធ នឹងរឿងក្តី

-ការអនុវត្តការលក់ ការទទួល និងការលក់នូវកម្មវត្ថុនៃសិទ្ធិទាមទារឱ្យប្រគល់នូវចលនវត្ថុដែលពាក់ព័ន្ធនឹងការរឹបអូស

-ការអនុវត្តការចាត់ចែងរក្សាការពារ -ការដេកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា(១)។

អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះយ៉ាងផុលផុស ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគនៃមាត្រាមួយចំនួនដើម្បីឱ្យកាន់តែសុក្រឹត។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលា។

## សេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# ការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិក្រមសីលធម៌ សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស

កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **លឹម អេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្ដីព្រាងអនុក្រឹត្យស្ដីពី ការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិក្រមសីលធម៌ សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស** ដោយមានការអញ្ជើញចូលរួមពីក្រសួងសុខាភិបាល សមាជិក និងអគ្គលេខាធិការរងនៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី។



ក្រសួងសុខាភិបាល បានស្នើឆ្លងប្រជុំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិក្រមសីលធម៌ សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស ដើម្បីបំពេញបន្ថែមសមាជិក នៃគណៈកម្មាធិការនេះ ពីព្រោះសមាជិកមួយចំនួនបានផ្លាស់ប្ដូរស្ថាប័ន និងទទួលអនិច្ចកម្ម។

យោងអនុក្រឹត្យលេខ៥៩ អនក្រ តត ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិក្រមសីលធម៌ សម្រាប់ការស្រាវជ្រាវដែលទាក់ទងនឹងមនុស្ស គណៈកម្មាធិការជាតិនេះ បានធ្វើការប្រជុំរៀងរាល់ ២ខែម្ដង ដើម្បីធ្វើការពិនិត្យវាយតម្លៃលើទិដ្ឋភាពក្រមសីលធម៌ គម្រោងសិក្សាស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស នៅកម្ពុជា។ គិតរហូតមកដល់ខែមិថុនា ឆ្នាំ២០១០ គណៈកម្មាធិការ បានពិនិត្យគម្រោងសរុប ៥៦១គម្រោង ដែលក្នុងនោះមានគម្រោងក្នុងប្រទេសចំនួន ៥០២ និងគម្រោងក្រៅប្រទេសចំនួន ៥៩ ហើយក្នុងនោះ គណៈកម្មាធិការ បានឯកភាពអនុញ្ញាតចំនួន ៤៤០គម្រោង និងឯកភាពអនុញ្ញាត ដោយមានលក្ខខណ្ឌកែសម្រួលឬព្យួរចំនួន ១២១គម្រោង។ លើសពីនេះទៅទៀត ក្នុងរយៈពេលកន្លងមក គណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស បានកសាងសមត្ថភាពរបស់គណៈកម្មាធិការផ្ទាល់ និងផ្សព្វផ្សាយឱ្យមានការយល់ដឹងបន្ថែមទៀតដល់មជ្ឈដ្ឋានអ្នកធ្វើការសិក្សាស្រាវជ្រាវនានាទាំងក្នុងនិងទាំងក្រៅប្រទេស។

រហូតមកដល់ពេលបច្ចុប្បន្ន គណៈកម្មាធិការជាតិគឺជាប្រកតែមួយគត់សម្រាប់ធ្វើការត្រួតពិនិត្យ វាយតម្លៃសីលធម៌



នៅលើរាល់គម្រោងសិក្សាស្រាវជ្រាវទាំងឡាយដែលទាក់ទងនឹងមនុស្សនៅកម្ពុជា ដោយជានិច្ចកាលឈរលើគោលការណ៍ណែនាំជាតិ និងអន្តរជាតិ[១]។

អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងអនុក្រឹត្យនេះយ៉ាងផុលផុស ហើយបានស្នើដល់ក្រសួងសាមី គួររៀបចំសេចក្តីព្រាងអនុក្រឹត្យនេះឡើងវិញឱ្យស្របទៅតាមស្តង់ដាដែលធ្លាប់ធ្វើកន្លងមក ចំពោះគណៈកម្មាធិការជាតិ (ខ្លឹមសារត្រូវមានកំណត់តួនាទី ភារកិច្ចរបស់គណៈកម្មាធិការជាតិ និងលេខាធិការដ្ឋាន) ព្រោះពេលនេះ យើងមានពេលវេលាគ្រប់គ្រាន់។ ក្រសួងសាមី បានឯកភាពចំពោះការស្នើនេះ ហើយជាលទ្ធផល អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារបង្កៀត មានសមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងក្រសួងសាមី ដើម្បីរៀបចំសេចក្តីព្រាងនេះឡើងវិញ។

អង្គប្រជុំជំនាញបច្ចេកទេស បានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះជាបណ្តោះអាសន្ន៕



[១] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិក្រមសីលធម៌ សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស។

# សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតកាយរឹទ្ធិជាតិកម្ពុជា

# និងសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានកាយរឹទ្ធិជាតិកម្ពុជា

កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ភូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតកាយរឹទ្ធិជាតិកម្ពុជា និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានកាយរឹទ្ធិជាតិកម្ពុជា ដោយមានការអញ្ជើញចូលរួមពីតំណាងសមាគមជាតិកាយរឹទ្ធិកម្ពុជា សមាជិក និងអគ្គលេខាធិការរងនៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

កាយរឹទ្ធិជាតិកម្ពុជា គឺជាអង្គការស្មគ្រចិត្តសម្រាប់កុមារ និងយុវជនមិនធ្វើនយោបាយ ហើយបើកចំហដល់ជនគ្រប់រូប ដោយមិនគិតអំពីដើមកំណើត សញ្ជាតិ ឬជំនឿ ដោយអនុលោមទៅតាមគោលបំណង គោលការណ៍ និងវិធីកាយរឹទ្ធិ។

គោលបំណងនៃកាយរឹទ្ធិជាតិកម្ពុជា គឺរួមចំណែកក្នុងការអប់រំកុមារ និងយុវជន ឱ្យមានសក្តានុពលពេញលេញខាងផ្លូវកាយ ផ្លូវបញ្ញា ផ្លូវសង្គម ផ្លូវចិត្ត និងផ្លូវអារម្មណ៍ភាព (emotion) ដើម្បីឱ្យក្លាយទៅជាពលរដ្ឋមានទំនួលខុសត្រូវ និងទៅជាសមាជិកក្នុងសហគមន៍តាមមូលដ្ឋានរស់នៅក្នុងសហគមន៍ជាតិ និងក្នុងសហគមន៍អន្តរជាតិ។

គោលការណ៍របស់កាយរឹទ្ធិជាតិកម្ពុជា គឺភ្ជាប់សកម្មភាពរបស់ខ្លួនទៅលើគោលការណ៍ជំនឿ គោលការណ៍សង្គម



អាកប្បកិរិយាបុគ្គលចំពោះសហគមន៍ និងការទទួលខុសត្រូវសម្រាប់ធ្វើឱ្យមានការលូតលាស់ដល់ខ្លួនឯងផ្ទាល់។ គោលការណ៍ទាំងអស់នេះស្តែងចេញឱ្យឃើញតាមរយៈភារកិច្ចចំពោះសាសនា ប្រទេសជាតិនិងមនុស្សផងទាំងពួង និងភារកិច្ចអភិវឌ្ឍខ្លួនឯងផ្ទាល់។

គោលបំណងនៃការរៀបចំតាក់តែងសេចក្តីព្រាងទាំងនេះ ដើម្បីឱ្យកាយរឹទ្ធិជាតិកម្ពុជាមានលិខិតបទដ្ឋានគតិយុត្តធានាបាននូវអភិបាលកិច្ចល្អក្នុងដំណើរការរបស់ខ្លួន និងអាចប្រើប្រាស់ថវិការដ្ឋបាន(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានគត់សម្គាល់ថា សេចក្តីព្រាងលិខិតបទដ្ឋានទាំងនេះមានលក្ខណៈស្មុគស្មាញក្នុងការកែសម្រួល និងរៀបចំខ្លឹមសារឡើងវិញក្នុងកិច្ចប្រជុំពេលនេះ ដូចនេះគួរបង្កើតអង្គប្រជុំចង្អៀតមួយ។ ជាលទ្ធផល អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារចង្អៀតមានសមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងសាមីស្ថាប័ន ដើម្បីរៀបចំសេចក្តីព្រាងទាំងនេះឡើងវិញ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារទាំងនេះជាបណ្តោះអាសន្ន៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតកាយរឹទ្ធិជាតិកម្ពុជា។

## ប្រជុំសារឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# ផលិតកម្មកសិកម្មតាមកិច្ចសន្យា

កាលពីថ្ងៃទី១០ និងទី២១ ខែកញ្ញា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងឯកឧត្តម **ឈន ព្រលឹង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក និង អគ្គលេខាធិការរងនៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



សូមរំឭកថា សេចក្តីព្រាងអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១០ ហើយអង្គប្រជុំនាពេលនោះ បានសម្រេចលើកពេលប្រជុំ ដើម្បីឱ្យក្រសួងសាមីពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធសិន។

អង្គប្រជុំជំនាញបច្ចេកទេសលើកនេះ បានផ្លាស់ប្តូរយោបល់លើសេចក្តីព្រាងអនុក្រឹត្យកែសម្រួលថ្មីនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគរបស់មាត្រា មួយចំនួន ដើម្បីឱ្យកាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបាន បញ្ចប់ការពិភាក្សា ជាបណ្តោះអាសន្ននៅជំពូកទី២ ៕

# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ សីហា ឆ្នាំ២០១០



កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំកិច្ចប្រជុំទូលាយនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ក្រោមអធិបតីភាពឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែសីហា ឆ្នាំ២០១០** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

- *សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ ក្នុងខែសីហា ឆ្នាំ២០១០នេះ កើនឡើង ០.៩% បើធៀបនឹងខែកក្កដា និងកើនឡើង ១.៧% ក្នុងរយៈពេល១២ខែ។* ក្នុងនោះក្រុមម្ហូបអាហារ ១មុខរួមចំណែក ៧៨% ទៅលើការកើនឡើងនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខនាខែនេះ និងក្រៅពីនោះក្រុមភោជនីយដ្ឋានរួមចំណែក ១៤% ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ ១.៨% និងសំលៀកបំពាក់ និងស្បែកជើង ២.២%។
- *កំណើនសន្ទស្សន៍ថ្លៃក្នុងខែកញ្ញានេះ ធ្វើឲ្យសន្ទស្សន៍ថ្លៃមធ្យមនៃទំនិញប្រើប្រាស់គ្រប់មុខ កើនឡើង ៤.៥% បើប្រៀបធៀបរយៈពេល ៨ខែដូចគ្នា ឆ្នាំ ២០១០/២០០៩។*
- បើពិនិត្យតាមក្រុមទំនិញវិញ ការប្រៀបធៀបខែ(សីហា/កក្កដា) បង្ហាញបំរែបំរួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ក្រុមដែលមានសន្ទស្សន៍ថ្លៃកើនឡើង (ក្នុងវង់ក្រចកៈ បំរែបំរួលក្នុងរយៈពេល១២ខែ) | ក្រុមដែលមានសន្ទស្សន៍ថ្លៃថយចុះ (ក្នុងវង់ក្រចកៈ បំរែបំរួលក្នុងរយៈពេល១២ខែ) |
|---|---|
| ▪ ម្ហូបអាហារៈ +១.៥% (+២.១% ) | ▪ ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀតៈ –០.១% (+២.៩%) |
| ▪ ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ៈ +១% (+១.៧%) | ▪ សុខាភិបាលៈ –០.៣% (–២.២%) |
| ▪ សំលៀកបំពាក់ និងស្បែកជើងៈ ០.៦% (–០.៣%) | ▪ ការដឹកជញ្ជូនៈ –០.២% (+២.២%) |
| ▪ គ្រឿងសង្ហារឹម និងសំភារៈប្រើប្រាស់ៈ +០.៥% (–០.១% ) | ▪ ទូរគមនាគមន៍ៈ –១.៤% (–៤.៧%) |
| ▪ ភោជនីយដ្ឋានៈ ២.១% (–០.១%) | ▪ ការកំសាន្ត និងវប្បធម៌ៈ –០.៥% (–០.១%) |
| ▪ ទំនិញ និងសេវាកម្មផ្សេងទៀតៈ ០.៣% (+៩.៦%) | |

តារាងខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខក្នុងអំឡុងពេល០៣ឆ្នាំចុងក្រោយ។ យើងសង្កេតឃើញថា បម្រែបម្រួលសន្ទស្សន៍ថ្លៃប្រចាំខែ ក្នុងឆ្នាំ២០១០ មាននិន្នាការរាងខុសពីឆ្នាំមុនៗ។

| ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១០ | 0.0% | 0.៣% | 0.៦% | -0.៣% | 0.២% | 0.0% | 0.៥% | 0.៩% | – | – | – | – | – |
| ២00៩ | -១.៥% | -0.១% | ១.៣% | ១.0% | ១.0% | ១.៩% | ១.៤% | 0.៧% | 0.៥% | -0.៣% | -0.៦% | -0.១% | -0.៧% |
| ២00៨ | ១.៨% | -0.៥% | ៨.៣% | ៤.៤% | ២.៩% | 0.៩% | 0.៥% | -0.៣% | -0.១% | -១.១% | -៣.៤% | -៣.៩% | ២៥% |

➤ ក្នុងខែសីហាឆ្នាំ២០១០នេះ អត្រាប្តូរប្រាក់ **៛/ដុល្លារ** ស្មើនឹង **៤,២៣៥៛/១ដុល្លារ** បើធៀបនឹងខែមុន អត្រាប្តូរប្រាក់ **៛/ដុល្លារ** ស្ថិតនៅស្ថិរ ប៉ុន្តែប្រាក់រៀលចុះថោក ២.២% ក្នុងរយៈពេល១២ខែ ។ អត្រាប្តូរប្រាក់ **៛/បាត** ស្មើនឹង **១៣៥៛/១បាត** បើធៀបនឹងខែមុន ប្រាក់រៀលចុះថោក ៣.១% ធៀបនឹងបាត និងចុះថោក ១១% ក្នុងរយៈពេល១២ខែ។ អត្រាប្តូរប្រាក់ **៛/ដុង** ស្មើនឹង **០.២១៧៛/១ដុង** បើធៀបនឹងខែមុន ប្រាក់រៀលឡើងថ្លៃ ២.៣% ធៀបនឹងដុង និង**ឡើងថ្លៃ ៦.៥%** ក្នុងរយៈពេល១២ខែ។

## ២) ស្ថានភាពថវិកាជាតិ

➤ *យោងតាមស្ថិតិដែលឆ្លងកាត់តេនាគារជាតិ **ចំណូលថវិកាជាតិ**ក្នុងខែសីហាឆ្នាំ២០១០នេះ **អនុវត្តបានចំនួន ៤៦៥.៧ ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ៧២% នៃគម្រោង) ក្នុងនោះ **ចំណូលមូលធន ៣.៩ ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ១១% នៃគម្រោង) និង**ចំណូលចរន្ត ៤៦១.៨ ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ៩៨% នៃគម្រោង)។*

➤ *បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ**ខែសីហា ថយចុះ១១% ប៉ុន្តែកើនឡើង ១២% ក្នុងរយៈពេល១២ខែ។* **ការថយចុះ**នាខែនេះ គឺបណ្តាលមកពីចំណូលមូលធន *ថយចុះ៦៣%* និងចំណូលចរន្ត*ថយចុះ១០%* ។

- ក្នុងចំណូលចរន្តនាខែសីហា ចំណូលសារពើពន្ធ*ថយចុះ៧.៥%* និងចំណូលមិនមែនសារពើពន្ធ*ថយចុះ២៣%* ។

| ក្នុងចំណូលសារពើពន្ធ | ក្នុងចំណូលមិនមែនសារពើពន្ធ |
|---|---|
| ✓ ពន្ធ និងអាករគយថយចុះ ៦.២%<br>✓ ចំណូលពន្ធដារថយចុះ ២.២%<br>✓ ចំណូលសារពើពន្ធផ្សេងៗថយចុះ ៨.៣% | ✓ ទេសាទ ថយចុះ ៦១%<br>✓ រុក្ខាប្រមាញ់កើនឡើង ៨៧%<br>✓សម្បទានរ៉ែ ថយចុះ ៤៤%<br>✓ អាកាសចរណ៍ស៊ីវិលកើនឡើង ៨៥២%<br>✓ ផលទុនទេសចរណ៍ កើនឡើង ៣៥%<br>✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ ថយចុះ ៧២%<br>✓ អាករស្ថានទូត ថយចុះ ១៤%<br>✓ ការត្រួតពិនិត្យគុណភាពផលិតផល កើនឡើង ២៥៨៣%<br>✓ ជួលពេងចក្រ សហគ្រាសថយចុះ ៤៣%<br>✓ ឯកជនភាវូបនីយកម្ម ថយចុះ ៩៨%<br>✓ ការលក់អចលនកម្ម ថយចុះ៦៥% |

➤ ***ចំណាយថវិកាជាតិ*** នៅខែសីហា ឆ្នាំ២០១០នេះ អនុវត្តបាន **៦៣០.៧ពាន់លានរៀល** (ជាមធ្យមប្រចាំខែ ស្មើនឹង ៦៧%នៃគម្រោង) ក្នុងនោះ **ចំណាយចរន្ត ៥៤៥.៩ពាន់លានរៀល** (ជាមធ្យមប្រចាំខែៈ ៨៨%នៃគម្រោង) និង**ចំណាយមូលធន ១៨៤.៨ពាន់លានរៀល** (ជាមធ្យមប្រចាំខែៈ ៣៤%នៃគម្រោង)។

➤ *បើធៀបនឹងខែមុន **ចំណាយថវិកាជាតិថយចុះ** ០.៩% ប៉ុន្តែកើនឡើង ១៥% ក្នុងរយៈពេល១២ខែ។* ការថយចុះក្នុងខែនេះ គឺបណ្តាលមកពីចំណាយចរន្ត*ថយចុះ ១៥%* ។ ចំណែកឯចំណាយមូលធន*កើនឡើង ៦៤%*។

➤ *តុល្យភាពថវិកាជាតិក្នុងខែ**សីហា**នេះមាន**ឱនភាព**ចំនួន **១៦៥.៣**ពាន់លានរៀល* ។

## ៣) ស្ថានភាពរូបិយវត្ថុ

➤ ក្នុងខែសីហាឆ្នាំ ២០១០ **រូបិយវត្ថុ** $M_2$ មានចំនួន *១៨,៦៧៥ពាន់លានរៀល កើនឡើង០.៩%* ធៀបនឹងខែមុន និង*កើនឡើង ៣០%* ក្នុងរយៈពេល១២ខែ ។ *ការកើនឡើងនៃ $M_2$ នាខែនេះ បណ្តាលមកពីការកើនឡើងនូវ រូបិយវត្ថុក្រៅធនាគារ ០.៤% ប្រាក់បញ្ញើចរន្ត ២៧% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ៤.៤% និងប្រាក់បញ្ញើជារូបិយបណ្ណ ០.៦%*។

➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** នាខែសីហាឆ្នាំ ២០១០នេះ មានចំនួន**២,៣៥៥ លានដុល្លារ** *កើនឡើង ០.២%* ធៀបនឹងខែមុន និង កើនឡើង ៩% ក្នុងរយៈពេល១២ខែ។

➢ ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលក្នុងខែសីហាឆ្នាំ ២០១០ មានចំនួន **២,៦៧៧ពាន់លានរៀល** ក្នុងនោះ ឥណទេយ្យចំពោះរាជរដ្ឋាភិបាល **២៧០ពាន់លានរៀល** និងប្រាក់បញ្ញើរាជរដ្ឋាភិបាល **២,៤០៦ពាន់លានរៀល**។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែសីហាឆ្នាំ ២០១០នេះ មានចំនួន **៧,៦៣០ ពាន់លានរៀល** កើនឡើង ៤.៣% បើធៀបនឹងខែមុន និងកើនឡើង ៣១% ក្នុងរយៈពេល ១២ខែ។

➢ ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជជារួមមានការកើនឡើងជាលំដាប់*** ឯក្នុងខែសីហានេះមានចំនួន ១២,៣០១ ពាន់លានរៀល កើនឡើង ១.៣% បើធៀបនឹងខែមុន និងកើនឡើង ២៣% ក្នុងរយៈបែល១២ខែ។

➢ ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** មានចំនួន **១,៥៥៧ ពាន់លានរៀល** កើនឡើង ៧.៤% បើធៀបនឹងខែមុន និងកើនឡើង ៣៨% ក្នុងរយៈពេល១២ខែ។

➢ អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ (អត្រាមធ្យមនៃធនាគារ ពាណិជ្ជទាំងអស់) ស្មើនឹង ៦.៥៨% ថយចុះ ០.៣% ធៀបនឹងខែមុន និងថយចុះ ៤.៤% ក្នុង រយៈពេល១២ខែ។

➢ អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជក្នុងខែសីហានេះស្មើនឹង **៤.៤៦%** ថយចុះ ១.១% ធៀបនឹងខែមុន និងថយចុះ ២៥% ក្នុងរយៈពេល១២ខែ។

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢ កសិកម្ម: ខែសីហា

- ផលិតកម្មនេសាទចំនួន **៣០ ពាន់តោន** ថយចុះ ១៤% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៤% ក្នុងរយៈពេល១២ខែ។

➢ ឧស្សាហកម្ម: ខែសីហា

- ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ១,១៣២ពាន់លានរៀល (បានពី១៧៣រោងចក្រ)។
- ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១៩៨.៥លានគីឡូវ៉ាត់ម៉ោង កើនឡើង ២.១% បើធៀបនឹងខែមុន និងកើនឡើង ១៤% ក្នុងរយៈពេល១២ខែ។

➢ សំណង់: ខែសីហា

- **សំណង់អនុញ្ញាតឲ្យសាងសង់**មានចំនួន ១៥០.៨ពាន់ម២ ថយចុះ ៣៣% បើធៀបនឹងខែមុន និង ថយចុះ៩០% ក្នុងរយៈពេល១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ៥២.៦លានដុល្លារ ថយចុះ ៣១% បើធៀបនឹងខែមុន និងថយចុះ ៨៨% ក្នុងរយៈពេល ១២ខែ។
- **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះគឺ **លំនៅឋាន** (៥៨%នៃសំណង់អនុញ្ញាតសរុប) និងឧស្សាហកម្ម (១៦%នៃសំណង់អនុញ្ញាតសរុប)។

➢ វិនិយោគ: នាខែសីហានេះគម្រោងវិនិយោគអនុញ្ញាតិដោយ គ.វ.ក. មានចំនួន **៣**។ បើគិតជា ទុនវិនិយោគ មានទឹកប្រាក់ស្មើនឹង **៩លានដុល្លារ** ថយចុះ ៩៦% បើធៀបនឹងខែមុន និងថយចុះ ៨៩% ក្នុងរយៈពេល ១២ខែ។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន **៥.៩ ពាន់នាក់**។

➢ សេវាកម្ម និងទេសចរណ៍: ខែសីហា

- **ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម**នៅក្រសួងពាណិជ្ជកម្មមានចំនួន ២២៤ កើនឡើង ១៣% បើធៀបនឹងខែមុន
- **ការដាក់ពាក្យរកការងារទៅក្រៅប្រទេសនៅក្រសួងការងារ**មានចំនួន ៤,០២៧នាក់ កើនឡើង ០.៨% បើធៀបនឹងខែមុន និងកើនឡើង ៦៤៩% ក្នុងរយៈពេល ១២ខែ។

▪ អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុនមានចំនួន ៣,៣០៦នាក់ ថយចុះ ៥៣% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ០.៥% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះទទួលបានការងារក្នុងប្រទេស មានចំនួន ១,២១៤នាក់ និងទទួលបានការងារក្រៅប្រទេស មានចំនួន ២,០៩២នាក់។

▪ **ទំនិញឆ្លងកាត់តាមផ្លូវសមុទ្រ** (សរុប៦ផែ) មានចំនួន ៣៣៥.៥ ពាន់តោនកើនឡើង ១.៣% បើធៀបនឹងខែមុន និង កើនឡើង ២១% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ

– ទំនិញឆ្លងកាត់ផែកំពង់សោមថយចុះ ៣.៣% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៧% ក្នុងរយៈពេល១២ខែ
– ទំនិញឆ្លងកាត់ផែឧកញ៉ាម៉ុងកើនឡើង ៥.៨% បើធៀបនឹងខែមុន និងកើនឡើង ៨.៥% ក្នុងរយៈពេល១២ខែ
– ទំនិញឆ្លងកាត់ផែស្រែអំបិល និងកោះកុងកើនឡើង ២៥៤% បើធៀបនឹងខែមុន ប៉ុន្តែថយចុះ ៥៧% ក្នុងរយៈពេល១២ខែ
–ទំនិញឆ្លងកាត់ផែភ្នំពេញថយចុះ កើនឡើង ៣។៩% និងកើនឡើង ១៤% ក្នុងរយៈពេល១២ខែ

▪ **អ្នកដំណើរតាមផ្លូវអាកាស** (អន្តរជាតិ) មានចំនួន ២៥៤ពាន់នាក់ កើនឡើង ១២% បើធៀបនឹងខែមុន និងកើនឡើង ២៧% ក្នុងរយៈពេល១២ខែ។

▪**ចំនួនអ្នកទេសចរកម្ពុជាចេញក្រៅប្រទេស**មាន៤៥៣ពាន់នាក់ កើនឡើង ១.៣% បើធៀបនឹងខែមុន និងកើនឡើង ៤៥% ក្នុងរយៈពេល១២ខែ។

▪ **ចំនួនអ្នកទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជា**មាន ២០៧ពាន់នាក់ កើនឡើង ២.១% បើធៀបនឹងខែមុន និងកើនឡើង ២០% ក្នុងរយៈពេល១២ខែ។

✓ អ្នកទេសចរតាមផ្លូវអាកាសមាន **១០៥ពាន់នាក់** កើនឡើង ៧.៤% បើធៀបនឹងខែមុន និងកើនឡើង ១៥% ក្នុងរយៈពេល ១២ខែ។

✓ អ្នកទេសចរតាមផ្លូវគោក និងទឹកមាន **១០២ពាន់នាក់** ថយចុះ ២.៩% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៣% ក្នុងរយៈពេល១២ខែ។

▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ (ក្នុងខែនេះមិនមានតួលេខ)

### ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➢យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែសីហាឆ្នាំ២០១០ មានចំនួន ១,៧៦១ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ ១៥% ប៉ុន្តែកើនឡើង ៣៧% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ៖

| **ទំនិញដែលកើនឡើង (សីហា/កក្កដា)** | **ទំនិញដែលថយចុះ (សីហា/កក្កដា)** |
|---|---|
| - ឧស្ម័ន +១២% | - ប្រេងឥន្ធនៈ –៣% |
| - ដែកសំណង់ +៣៩% | - ស៊ីម៉ង់ –១៨% |
| - ស្រូវសាលី +៨.៣% | - រថយន្តសរុប (ពាន់លានរៀល) –៣០% |
| - អង្ករ +៧៦% | - គ្រាក់ទ័រនិងគោយន្ត –៣០% |
| - ផ្លែឈើនិងបន្លែ +៣១% | - នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ –៣៧% |
| - ជីនិងថ្នាំកសិកម្ម +២.៨% | |

➢**ការនាំចេញ** ក្នុងខែសីហាឆ្នាំ២០១០ មានចំនួន ១,៤៤៨ពាន់លានរៀល ថយចុះ ១២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២០% ក្នុងរយៈពេល១២ខែ។ ក្នុងនោះការនាំចេញដែលថយចុះមាន ផលិតផលវាយនភណ្ឌនិងស្បែកជើង ១៥% អង្ករ ១០% និងផលិតផលនេសាទ ៨៣%។ ការនាំចេញដែលកើនឡើងមាន ផលិតផលឈើកែច្នៃ ៣៤% និងកៅស៊ូ ៣៧%។

➢ *ក្នុងខែសីហាឆ្នាំ២០១០នេះជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ៣១៣ពាន់លានរៀល។*

## ៦. កំណត់សម្គាល់សំខាន់ៗ

### ៦.១. បញ្ហាសំខាន់ៗ នៃស្មារតីអង្គប្រជុំ

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

**សន្ទស្សន៍ថ្លៃទំនិញៈ** នាខែសីហានេះ ថ្លៃទំនិញ និងសេវាកម្មគ្រប់មុខកើនឡើងដល់កំរិតមួយខ្ពស់ ដែលមិនធ្លាប់មាន ចាប់តាំងពីដើមឆ្នាំ ២០១០មក។ ក្រុមម្ហូបអាហារ បានរួមចំណែកខ្លាំងជាងគេលើការកើនឡើងនៃអត្រាថ្លៃសរុបនេះ។ ក្នុងចំណោមក្រុមម្ហូបអាហារ **បើគិតពីគ្រាគោល ឆ្នាំ២០០៦** មកដល់ខែសីហា ឆ្នាំ២០១០ អង្ករបានឡើងថ្លៃជិតពីរដង(៨១%) និងក្រៅពីនោះ សាច់មាន់ ៦២% សាច់ជ្រូក ៥៥% ត្រីស្រស់ ៣៨% សាច់គោ ៣៦% ត្រីស្រស់ ៣៨% ផ្លែឈើ ៤០% និងបន្លែ ៤៥%។



### ៦.២. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែសីហា ឆ្នាំ២០១០នេះ សូចនាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | ធៀបនឹងខែមុន | ក្នុងរយៈពេល១២ខែ | ផ្សេងៗ |
|---|---|---|---|
| ១. ថ្លៃត្រីស្រស់ | +៨.៤% | +៧.៧% | – |
| ២. ពន្ធលើប្រាក់បៀវត្ស | +៤៩% | +៥៥% | – |
| ៣. ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | +៩១% | +១៥២% | – |
| ៤. ចំណូលពីការត្រួតពិនិត្យគុណភាពផលិតផល | +២៥៣៣% | +២៣៤% | – |
| ៥. សំណង់អនុញ្ញាតអោយសាងសង់ (ពាន់ម²) | –៣៣% | –៩០% | មានការថយចុះខ្លាំង នូវសំណង់ពាណិជ្ជកម្ម និងសំណង់សាធារណៈ |
| ៦. គំរោងវិនិយោគអនុញ្ញាតដោយ គ.វ.ក. (ទុន) | –៩៦% | –៨៩% | – |
| ៧. នាំចេញផលិតផលឈើកែច្នៃ | +៣៤% | +២១៨១% | – |
| ៨. នាំចេញអង្ករ | –១០% | +៤៧៣% | – |

#### កំណត់សំគាល់

- ព័ត៌មាន និងទិន្នន័យពណ៌ បៃតង សំដៅលទ្ធផលល្អ
- ព័ត៌មាន និងទិន្នន័យពណ៌ ក្រហម សំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យ៉េង ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៩/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតជាន់ខ្ពស់ជំនាន់ទី២ និស្សិតបរិញ្ញាបត្រជំនាន់ទី៥ និងវិញ្ញាបនបត្រសិក្សាដល់សិក្ខាកាមជំនាន់ទី២៧ នៃសាកលវិទ្យាល័យធនធានមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានជាតិអប់រំ ខាងជើងវិមានឯករាជ្យ។ |
| ២ | ០២/០៩/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងមហាសន្និបាតសាមញ្ញ របស់សមាគមជាតិកាយរឹទ្ធកម្ពុជាលើកទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៣/០៩/១០ ព្រឹក | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម៖<br>១- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការប្រមូល និងការចងក្រងព័ត៌មានទីផ្សារការងារ<br>២- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិជនពិការ<br>៣- បញ្ហាផ្សេងៗ |
| ៤ | ០៦/០៩/១០ ព្រឹក | ប្រជុំពិភាក្សាការងារជាមួយ ARTISAN ANGKOR នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៦/០៩/១០ ល្ងាច | ប្រជុំពិភាក្សា អំពីបុរីរដ្ឋបាលប្រមូលផ្តុំខេត្តសៀមរាប ជាមួយឯកឧត្តម **ម៉ម សុផាណា** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៨/០៩/១០ ព្រឹក-ល្ងាច | ប្រជុំពិភាក្សា អំពីបុរីរដ្ឋបាលប្រមូលផ្តុំខេត្តសៀមរាប នៅខេត្តសៀមរាប។ |
| ៧ | ០៩/០៩/១០ល្ងាច | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១- អនុក្រឹត្យស្តីពី ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី។<br>២- អនុក្រឹត្យស្តីពី ការបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន។<br>៣- បញ្ហាផ្សេងៗ<br>ដើម្បីត្រៀមប្រជុំជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១០/០៩/១០ ព្រឹក | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយសម្រាប់ត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១- អនុក្រឹត្យស្តីពី ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី។<br>២- អនុក្រឹត្យស្តីពី ការបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន។<br>៣- បញ្ហាផ្សេងៗ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ១៤/០៩/១០ ព្រឹក | ប្រជុំពិភាក្សាការងារជាមួយលោក VINCENT PIRON (SCA) នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៦/០៩/១០ ព្រឹក | អញ្ជើញចូលរួមក្នុងពិធីបញ្ចុះបឋមសិលា សម្រាប់គម្រោងសាងសង់សារមន្ទីរវាំយនកណ្តប្រពៃណីអាស៊ី ក្រោមអធិបតីភាព លោកជំទាវប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌា នៅបូរីវប្បធម៌ និងទេសចរណ៍ក្រុងសៀមរាប។ |
| ១១ | ១៦/០៩/១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀង ជូនលោកជំទាវប្រធានាធិបតី និងគណៈប្រតិភូនៃសាធារណរដ្ឋឥណ្ឌា នៅសណ្ឋាគារសុខា។ |
| ១២ | ២០/០៩/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធ ស្ពានព្រែកព្នៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ |
| ១៣ | ២២/០៩/១០ ថ្ងៃត្រង់ | ចូលរួមជាកិត្តិយសក្នុងពិធីជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ អញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលនៃមេដឹកនាំអាស៊ាន-អាមេរិក ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងញូវយ៉ក នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៤ | ២៧/០៩/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីថ្វាយព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យ ស្តេចយាងទៅកាន់សាធារណរដ្ឋប្រជាមានិតចិន នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៥ | ២៧/០៩/១០ ម៉ោង ១០:០០ | ជាអធិបតីក្នុងបទបង្ហាញ ស្តីពីជំនួយខ្យល់ និងបែបបទសុំជំនួយពីបរទេសដែលបង្ហាញដោយ ឯកឧត្តម **សុន គន្ធរ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៨/០៩/១០ ព្រឹក | ចូលរួមក្នុងកិច្ចប្រជុំពិភាក្សារៀបចំដំណើរការផ្សារ **កសិផល សុខ អាន ទន្លាប់** មជ្ឈមណ្ឌលភូមិមួយផលិតផលមួយ នៅស្រុកគីរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៧ | ២៩/០៩/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ជូនដល់និស្សិតនៃសាកលវិទ្យាល័យពុទ្ធិសាស្រ្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលវប្បធម៌សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នៅវិទ្យាស្ថានជាតិអប់រំ ខាងជើងវិមានឯករាជ្យ។ |
| ១៨ | ២៩/០៩/១០ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលេខ២ នៃកិច្ចព្រមព្រៀងផ្តល់ជំនួយ សម្រាប់កម្មវិធីកំណើនសេដ្ឋកិច្ច រវាងរាជរដ្ឋាភិបាលកម្ពុជា និងភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ៣០/០៩/១០ ព្រឹក | ដឹកនាំអង្គប្រជុំទូលាយ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | ៣០/០៩/១០ល្ងាច | ប្រជុំពិភាក្សាការងារជាមួយ Mr. Nicolas Deviller និង Mr. Gardere អំពីអាទីហ្សង់អង្គរ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម គីម សយសាម៉ាឡៃន អនុប្រធាន ECOSOCC ប្រចាំខែកញ្ញា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០.០៩.១០ | ប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ |
| ២ | ២៩/០៩/១០ | ចូលរួមក្នុងពិធីប្រគល់ និងទទួលសៀវភៅសាលក្រម សំណុំរឿងលេខ ០០១ កាំងហ្កេកអ៊ាវ ហៅ ឌុច ជូនដល់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៩/០៩/១០ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលេខ២ នៃកិច្ចព្រមព្រៀងផ្តល់ជំនួយ សម្រាប់កម្មវិធីកំណើនសេដ្ឋកិច្ច រវាងរាជរដ្ឋាភិបាលកម្ពុជា និងភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ៣០.០៩.១០ | ពិធីចុះហត្ថលេខាលើ MOU ស្តីពីគម្រោងពន្លឿនសេដ្ឋកិច្ចកម្ពុជា និង NiDA និងក្រុមហ៊ុន ZTE Corporation ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលសន អនុប្រធាន ECOSOCC ប្រចាំខែកញ្ញា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៩/១០ | ចូលរួមជាកិត្តិយសក្នុងមហាសន្និបាតសាមញ្ញ របស់សមាគមជាតិកាយរឹទ្ធកម្ពុជាលើកទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈ រដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៦.០៩.១០ | ចូលរួមជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈ រដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យលោក Olaf Unteroberdoerster និងលោកស្រី Li Lian Ong គណៈប្រតិភូ IMF ចូលជួបសវនាការលើប្រធានបទស្តីពី៖<br>១-ការអភិវឌ្ឍសេដ្ឋកិច្ចនាពេលថ្មីៗរបស់កម្ពុជា និងទស្សនៈវិស័យនាពេលខាងមុខ<br>២-ការធ្វើសម្បទានរ៉ែ និងប្រេង និងទស្សនៈវិស័យសម្រាប់ផលិតផលទាំងនេះ<br>៣-កំណែទម្រង់មន្ត្រីរាជការស៊ីវិល និងច្បាប់ប្រឆាំងអំពើពុករលួយ |
| ៣ | ២៧.០៩.១០ | ស្តាប់បទបង្ហាញ ស្តីពីជំនួយខ្យល់ និងបែបបទសុំជំនួយពីបរទេស ដែលបង្ហាញដោយឯកឧត្តម សុន គន្ធូ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៩/០៩/១០ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលេខ២ នៃកិច្ចព្រមព្រៀងផ្តល់ជំនួយ សម្រាប់កម្មវិធីកំណើនសេដ្ឋកិច្ច រវាងរាជរដ្ឋាភិបាលកម្ពុជា និងភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ២៩/០៩/១០ | ចូលរួមក្នុងពិធីប្រគល់ និងទទួលសៀវភៅសាលក្រម សំណុំរឿងលេខ ០០១ កាំងហ្កេកអ៊ាវ ហៅ ឌុច ជូនដល់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ សមាជិក-សមាជិកា
## សកម្មភាក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៩/០៨/១០ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារប្រចាំខែកក្កដា របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |
| ២ | ១១/០៨/១០ | ឯកឧត្តម **ឡុង ឈាង** ចូលរួមក្នុងពិធីបើកកិច្ចប្រជុំស្តីពីការអនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការ និងការការពារតំបន់ជុំវិញបឹងទន្លេសាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **យឹម ឆាយលី** ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។ |
| ៣ | ១១/០៨/១០ | ឯកឧត្តម **ឡុង ឈាង** ចូលរួមក្នុងពិធីបិទកិច្ចប្រជុំស្តីពីការអនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការ និងការការពារតំបន់ជុំវិញបឹងទន្លេសាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ |
| ៤ | ០៣.០៩.១០ | ឯកឧត្តម **ម៉ម សារិទ្ធ** ចូលរួមប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ឧបាស្រ័យពាណិជ្ជកម្ម នៅសណ្ឋាគារ កាំបូឌីយ៉ានណា។ |
| ៥ | ០៨/០៩/១០ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារប្រចាំខែសីហា របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |



រូបភាពក្នុងបទបង្ហាញស្តីពី ជំនួយខ្យល់ និងការរៀបចំគម្រោងវិនិយោគ

## បទបង្ហាញស្ដីពី

# ជំនួយខ្យល់ និងការរៀបចំគម្រោងវិនិយោគ

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ECOSOCC ) នៃទីស្ដីការគណៈរដ្ឋមន្ត្រី បានអញ្ជើញ ឯកឧត្តម **សុន គន្ធរ** ទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា អគ្គលេខាធិការនៃគណៈកម្មាធិការជាតិជំរុញចលនា ភ១ ផ១ និងឯកឧត្តម **ម៉ី កល្យាណ** ទីប្រឹក្សាអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ជំរុញចលនាភូមិមួយផលិតផលមួយ និងធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីធ្វើបទបង្ហាញចំនួន ០២គឺ ១-ជំនួយខ្យល់ និង២-ការរៀបចំ គម្រោងវិនិយោគ ជូនសមាជិក និងមន្ត្រីនៃ ECOSOCC សមាជិក និងមន្ត្រីខ្លះនៃក្រុមប្រឹក្សាអ្នកច្បាប់ ដែលបានប្រព្រឹត្តទៅនៅថ្ងៃចន្ទ ទី២៧ ខែកញ្ញា ឆ្នាំ២០១០ វេលាម៉ោង ៩:០០នាទី ក្រោមអធិបតីភាពឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុក បេសកកម្មពិសេស ប្រធាន ECOSOCC ។

ឯកឧត្តម **សុន គន្ធរ** បានធ្វើបទបង្ហាញស្ដីពីជំនួយខ្យល់ ដោយបានលើកឡើងនូវចំណុចសំខាន់ៗដូចខាងក្រោមនេះ ៖



១-និយមន័យ៖ គម្រោងខ្យល់ ឬជំនួយខ្យល់ គឺសំដៅទៅលើគម្រោង ឬជំនួយដែលពុំមានសកម្មភាព ហើយធ្វើឡើង សម្រាប់ទាមទារលិខិតធានាគារ ឬពីរដ្ឋាភិបាល។

២-គោលបំណងមួយចំនួននៃការប្រកាសជំនួយខ្យល់៖ អ្នកប្រកាសជំនួយខ្យល់ដែលមានទឹកប្រាក់ច្រើនលានដុល្លារ គឺចង់បានលិខិតធានាពីធនាគាររដ្ឋ ឬពីរដ្ឋាភិបាល ដើម្បីប្រើប្រាស់ ជាមធ្យោបាយក្លែងបន្លំ និងសម្រេចគោលបំណងអាក្រក់មួយចំនួនដូចជា ( គេចកាតព្វកិច្ចបង់ពន្ធ រកប្រាក់កម្ចី លាងសំអាតប្រាក់កខ្វក់ ) ជាដើម។

៣-សកម្មភាពផ្សេងទៀតនៃការប្រកាសជំនួយខ្យល់៖ នៅមានសកម្មភាពខ្លះទៀតជាបោកប្រាស់ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងជំនួយខ្យល់ដែរ គឺការប្រកាសផ្ដល់ជំនួយលើគម្រោងអភិវឌ្ឍធំៗ ដោយមានអ្នករត់ការបញ្ចុះបញ្ចូល ការប្រកាសពីការឈ្នះរង្វាន់ ឬត្រូវបឆ្នោតតាមប្រព័ន្ធ E-mail-Internet ការសុំឱ្យជួយដល់ដំណើរការផ្ទេរប្រាក់តាមប្រព័ន្ធ E-mail-Internet ដោយសន្យាជូនជាសគុណ និងហិរញ្ញប្បទាន ព្រមទាំងជំនួយសម្រាប់គេវរកម្ម។

បទបង្ហាញនេះបានផ្ដល់ជាឧទាហរណ៍នូវទម្រង់សំខាន់ៗខ្លះនៃប្រព័ន្ធហិរញ្ញប្បទានមួយបែបដែលគ្រាន់តែជាការប្រកាសពីបុគ្គល ឬពីស្ថាប័នដែលមានប្រភពមិនច្បាស់លាស់ ហើយដែលប្រព័ន្ធបោកប្រាស់នេះកំពុងតែរីកដុះដាលយ៉ាងខ្លាំង ទាំងនៅក្នុងបណ្ដាលប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសរីកចម្រើនខ្លះ។

ការបោកប្រាស់ខាងលើ បានធ្វើឱ្យពាណិជ្ជករខ្មែរ មន្ត្រីរាជការនិងឈ្មួញកណ្ដាលមួយចំនួនខាតបង់ប្រាក់កាស និងពេលវេលា គួរឱ្យសោកស្ដាយជាទីបំផុត។

ឯកឧត្តម **ម៉ី កល្យាណី** បានធ្វើបទបង្ហាញស្ដីពីការរៀបចំគម្រោងវិនិយោគ ដោយបានលើកឡើងនូវចំណុចសំខាន់ខ្លះៗ ដូចខាងក្រោមនេះ៖

១-គម្រោងវិនិយោគ ៖ សកម្មភាពបច្ចុប្បន្ន ទទួលផលនៅពេលអនាគត។

២-គម្រោង ៖ សកម្មភាពដោយប្រុងប្រយត្នតាមផែនការកំណត់ដើម្បីសម្រេចគោលបំណងជាក់លាក់មួយ។

៣-គម្រោងកើតចេញមកពីការស្រមើលស្រម៉ៃរបស់អ្នកដឹកនាំគោលនយោបាយ ការវិភាគម៉ត់ចត់ និងដំណើរការធ្វើ ផែនការរបស់ក្រសួងពាក់ព័ន្ធគោលនយោបាយរបស់ដៃគូអភិវឌ្ឍន៍ តម្រូវការនិងគំនិតផ្ដួចផ្ដើមក្នុងស្រុក។

៤-ការអនុវត្តគម្រោងនីមួយៗត្រូវការអ្នកឯកទេសដែលពាក់ព័ន្ធជាច្រើនដែលមានជំនាញឯកទេសផ្សេងៗគ្នា។

៥-គម្រោងត្រូវមានហេតុផលឱ្យបានច្បាស់លាស់ និងបញ្ជាក់ពីឧបសគ្គ និងឱកាស។

ឯកឧត្តម បានលើកឧទាហរណ៍ពីគម្រោងសូត្រនៅកម្ពុជា ដែលឯកឧត្តមជានាយកគម្រោងនេះ៕

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម Ék]tm Km sysm Lp | អនុប្រធាន ក.ស.វ |
| និពន្ធនាយក ៖ | ឯកឧត្តម Ék]tm vg sGg | អគ្គលេខាធិការ ក.ស.វ |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | ឯកឧត្តម Ék]tm m sT | សមាជិកបម្រុង ក.ស.វ |
| និពន្ធអក្ខរាវិរុទ្ធ ៖ | ឯកឧត្តម Ék]tm Gg tm | អគ្គលេខាធិការរង ក.ស.វ |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | Lk sy vs | ប្រធានការិយាល័យ ក.ស.វ |
| យកព័ត៌មាន និងថតរូប ៖ | Lk hg P3bP | ប្រធានការិយាល័យ ក.ស.វ |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | Lk k Ett | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក.ស.វ |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasnaarrow@gmail.com